**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ : ៣៤៩ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការអនុវត្តកម្មវិធីជាតិជំនួយសង្គមផ្នែកបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និងបច្ចេកទេស សម្រាប់យុវជនមកពីគ្រួសារក្រីក្រ និងគ្រួសារងាយរងហានិភ័យ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងផែនការ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០២ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០១ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧២៣/១៥៦៣ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២៣ ស្តីពីការបង្កើតគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦១៧/៤៨៨ ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៧ ស្តីពីការបង្កើតក្រុមប្រឹក្សាជាតិគាំពារសង្គម
- បានឃើញអនុក្រឹត្យលេខ២២៤ អនក្រ.បក ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២១ ស្តីពីការបង្កើតមូលនិធិហិរញ្ញប្បទានគាំពារសង្គម
- បានឃើញអនុក្រឹត្យលេខ៦៨ អនក្រ.បក ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២២ ស្តីពីការបង្កើតមូលនិធិជាតិជំនួយសង្គមជាគ្រឹះស្ថានសាធារណៈរដ្ឋបាល
- យោងតាមការស្នើសុំរបស់ប្រធានក្រុមប្រឹក្សាជាតិគាំពារសង្គម។

## សម្រេច

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១**.-

អនុក្រឹត្យនេះ មានគោលបំណងកំណត់អំពីវិធាន នីតិវិធី និងយន្តការគ្រប់គ្រងការអនុវត្តកម្មវិធីជាតិជំនួយសង្គមផ្នែកបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និងបច្ចេកទេស សម្រាប់យុវជនមកពីគ្រួសារក្រីក្រ និងគ្រួសារងាយរងហានិភ័យ ដើម្បីផ្តល់ឱកាសស្មើគ្នាជូនយុវជនក្នុងការទទួលបានការអភិវឌ្ឍជំនាញ និងឱកាសការងារកាន់តែល្អប្រសើរក្នុងការបង្កើនប្រាក់ចំណូល និងជីវភាពរស់នៅ។

**មាត្រា២**.-

អនុក្រឹត្យនេះ មានវិសាលភាពអនុវត្តចំពោះយុវជនមកពីគ្រួសារក្រីក្រដែលមានបណ្ណសមធម៌ និងគ្រួសារងាយរងហានិភ័យដែលមានបណ្ណសម្គាល់គ្រួសារងាយរងហានិភ័យ នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា៣**.-

វាក្យសព្ទបច្ចេកទេសដែលប្រើក្នុងអនុក្រឹត្យនេះ មាននិយមន័យ ដូចខាងក្រោម៖

- **បណ្ណសមធម៌ និងបណ្ណសម្គាល់គ្រួសារងាយរងហានិភ័យ** សំដៅដល់បណ្ណដែលចេញដោយក្រសួងផែនការ តាមរយៈយន្តការកំណត់អត្តសញ្ញាណគ្រួសារក្រីក្រ
- **សន្ធានកម្មនៃកម្មវិធីកុំព្យូទ័រ** (API) សំដៅដល់ច្រកចេញ-ចូលនៃទំនាក់ទំនងក្នុងការផ្លាស់ប្តូរទិន្នន័យរវាងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានពីរ ឬច្រើន។

## ជំពូកទី២
## គោលការណ៍ និងយន្តការគ្រប់គ្រងកម្មវិធី
### ផ្នែកទី ១
### ការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និងបច្ចេកទេស

**មាត្រា៤**.-

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ទទួលខុសត្រូវ ក្នុងការចុះឈ្មោះចូលរៀនក្នុងកម្មវិធី និងបញ្ជាក់លក្ខខណ្ឌសិក្សារបស់យុវជនមកពីគ្រួសារមានបណ្ណសមធម៌ និងបណ្ណសម្គាល់គ្រួសារងាយរងហានិភ័យ តាមរយៈគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ។ ទិន្នន័យនៃការចុះឈ្មោះចូលរៀនក្នុងកម្មវិធី និងការបញ្ជាក់លក្ខខណ្ឌសិក្សា ត្រូវបញ្ជូនមកមូលនិធិជាតិជំនួយសង្គម។

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ទទួលខុសត្រូវដោះស្រាយបញ្ហានានា នៅក្នុងដំណាក់កាលនៃការចុះឈ្មោះចូលរៀនក្នុងកម្មវិធី ការបញ្ជាក់លក្ខខណ្ឌសិក្សា និងការសិក្សា។

**មាត្រា៥.-**

មូលនិធិជាតិជំនួយសង្គម ទទួលខុសត្រូវ ក្នុងការបើកផ្ដល់ប្រាក់ឧបត្ថម្ភដល់យុវជនក្នុងគ្រួសារមានបណ្ណសមធម៌ និងបណ្ណសម្គាល់គ្រួសារងាយរងហានិភ័យ និងត្រូវចែករំលែកទិន្នន័យនៃការបើកផ្ដល់តាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងកម្មវិធី ទៅក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

មូលនិធិជាតិជំនួយសង្គម ទទួលខុសត្រូវដោះស្រាយបញ្ហានានា នៅក្នុងដំណាក់កាលនៃការបើកផ្ដល់ប្រាក់ឧបត្ថម្ភ។

**មាត្រា៦.-**

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មូលនិធិជាតិជំនួយសង្គម និងក្រសួងផែនការ ត្រូវធ្វើសន្ធានកម្មនៃកម្មវិធីកុំព្យូទ័រ (API) រវាងមូលដ្ឋានទិន្នន័យគ្រប់គ្រងដោយក្រសួង-ស្ថាប័ននីមួយៗសម្រាប់អនុវត្តកម្មវិធី។

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងមូលនិធិជាតិជំនួយសង្គម ត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្ត ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងកម្មវិធី សៀវភៅប្រតិបត្តិគោលស្ដីពីការអនុវត្តកម្មវិធី ផែនការបណ្តុះបណ្តាល និងការអភិវឌ្ឍសមត្ថភាព និងរាល់ឯកសារពាក់ព័ន្ធនឹងការអនុវត្តកម្មវិធី ដើម្បីគ្រប់គ្រង និងអនុវត្តកម្មវិធី ប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផល។

## ផ្នែកទី ២
## ការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈដូនតា

**មាត្រា៧.-**

ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ទទួលខុសត្រូវ ក្នុងការចុះឈ្មោះចូលរៀនក្នុងកម្មវិធីសិក្សាជំនាញវិជ្ជាជីវៈដូនតា និងបញ្ជាក់លក្ខខណ្ឌសិក្សារបស់យុវជនមកពីគ្រួសារមានបណ្ណសមធម៌ និងបណ្ណសម្គាល់គ្រួសារងាយរងហានិភ័យ តាមរយៈគ្រឹះស្ថានអប់រំបណ្តុះបណ្តាល និងសាលាបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈដូនតា នៅតាមសហគមន៍ ដែលទទួលស្គាល់ដោយក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ។

ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ទទួលខុសត្រូវដោះស្រាយបញ្ហានានា នៅក្នុងដំណាក់កាលនៃការចុះឈ្មោះចូលរៀនក្នុងកម្មវិធី ការបញ្ជាក់លក្ខខណ្ឌសិក្សា និងការសិក្សា។

**មាត្រា៨.-**

ប្រាក់ឧបត្ថម្ភ យន្តការ និងនីតិវិធីបើកផ្ដល់ប្រាក់ឧបត្ថម្ភ សម្រាប់ការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈដូនតា ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តដោយឡែក។

## ជំពូកទី៣
## លក្ខខណ្ឌនៃការទទួលផល និងអត្ថប្រយោជន៍

**មាត្រា៩.-**

យុវជនមកពីគ្រួសារក្រីក្រ និងគ្រួសារងាយរងហានិភ័យ ត្រូវបំពេញលក្ខខណ្ឌគោល ដូចខាងក្រោម៖

- មានអាយុចាប់ពី១៥ឆ្នាំឡើងទៅ
- មានបណ្ណសមធម៌ ឬបណ្ណសម្គាល់គ្រួសារងាយរងហានិភ័យ ដែលមានសុពលភាព

**មាត្រា១០.-**

យុវជនមកពីគ្រួសារក្រីក្រ និងគ្រួសារងាយរងហានិភ័យ ត្រូវទទួលបានអត្ថប្រយោជន៍ និងប្រាក់ឧបត្ថម្ភ ដូចខាងក្រោម៖

- ទទួលបានការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និងបច្ចេកទេស និងការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈជូនតា ដោយមិនបង់ថ្លៃ និងការផ្តល់សេវាពាក់ព័ន្ធនឹងឱកាសការងារ
- ទទួលបានប្រាក់ឧបត្ថម្ភចំនួន **២៨០ ០០០ (ពីររយប៉ែតសិបពាន់) រៀល** ក្នុងមួយខែ ដោយសិក្សាពេញម៉ោង រយៈពេល ៤ខែ ដោយភ្ជាប់ជាមួយការបំពេញលក្ខខណ្ឌវត្តមានតាមការកំណត់។ ក្នុងករណីវគ្គសិក្សានៅវេនយប់ និងចុងសប្តាហ៍ ប្រាក់ឧបត្ថម្ភនឹងត្រូវកំណត់ក្នុងសៀវភៅប្រតិបត្តិគោលស្តីពីការអនុវត្តកម្មវិធី។ សម្រាប់ការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និងបច្ចេកទេស ការផ្តល់ប្រាក់ឧបត្ថម្ភមិនត្រូវលើសពី **១ ១២០ ០០០ (មួយលានមួយរយម្ភៃពាន់) រៀល** ក្នុង**១ វគ្គសិក្សា**។

នីតិវិធីនៃការចុះឈ្មោះចូលរៀនក្នុងកម្មវិធី លក្ខខណ្ឌនៃការទទួលផល និងការធ្វើបច្ចុប្បន្នភាពទិន្នន័យវត្តមានប្រចាំខែ ត្រូវកំណត់ក្នុងសៀវភៅប្រតិបត្តិគោលស្តីពីការអនុវត្តកម្មវិធី។

## ជំពូកទី៤
## តួនាទី និងភារកិច្ចរបស់ក្រសួង ស្ថាប័នដឹកនាំ ក្នុងការអនុវត្តកម្មវិធី

**មាត្រា១១**.-

គណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលមានអគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាសេនាធិការ មានតួនាទី និងភារកិច្ចដូចខាងក្រោម៖

- ផ្តល់ការណែនាំ និងតម្រង់ទិសផ្នែកគោលនយោបាយសម្រាប់កម្មវិធី
- ផ្តល់មតិយោបល់លើការគ្រោងថវិកាសម្រាប់កម្មវិធី។

**មាត្រា១២**.-

អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម (អ.ក.គ.) មានតួនាទី និងភារកិច្ច ដូចខាងក្រោម៖

- សម្របសម្រួលជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ ដើម្បីអនុវត្តកម្មវិធីឱ្យបានរលូន និងជោគជ័យ
- ចងក្រងរបាយការណ៍ពីក្រសួង-ស្ថាប័នអនុវត្តកម្មវិធី និងរាយការណ៍ជូនក្រុមប្រឹក្សាជាតិគាំពារសង្គម និងគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- សម្របសម្រួលលើការអនុវត្តថវិកាតាមរយៈមូលនិធិហិរញ្ញប្បទានគាំពារសង្គម (ម.គ.ស)
- ដឹកនាំការត្រួតពិនិត្យ តាមដាន និងវាយតម្លៃកម្មវិធី។

**មាត្រា១៣**.-

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មានតួនាទី និងភារកិច្ច ដូចខាងក្រោម៖

- ទំនាក់ទំនង កៀរគរ និងបញ្ជ្រាបការយល់ដឹង និងព័ត៌មានអំពីកម្មវិធីដល់យុវជនគោលដៅ អាជ្ញាធរមូលដ្ឋាន គ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ និងរោងចក្រ សហគ្រាស
- រៀបចំកម្មវិធីសិក្សា និងផ្តល់វគ្គបណ្តុះបណ្តាលជូនយុវជនគោលដៅ ប្រកបដោយគុណភាព និងភាពសមស្រប
- អនុវត្តការងារចាំបាច់សម្រាប់អនុវត្តកម្មវិធី ចាប់ពីការចុះឈ្មោះចូលរៀនក្នុងកម្មវិធី រហូតដល់ការផ្តល់សេវាប្រឹក្សាការងារ
- គ្រប់គ្រង និងសម្របសម្រួលជាមួយគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ និងរោងចក្រ សហគ្រាស

- សម្របសម្រួលជាមួយក្រសួង-ស្ថាប័ន វិស័យឯកជន និងនិយោជក ដើម្បីជំរុញចុះកម្មសិក្សា និងឱកាសការងារ
- សហការជាមួយក្រសួង-ស្ថាប័ន និងភាគីពាក់ព័ន្ធ ដើម្បីដោះស្រាយមតិជំទាស់ និងការតវ៉ារបស់អ្នកទទួលផល
- រៀបចំផែនការ និងប៉ាន់ស្មានតម្រូវការថវិកាសម្រាប់ការបណ្តុះបណ្តាល និងការផ្តល់សេវានានា ក្រោមកម្មវិធី
- សហការ និងចូលរួមដំណើរការពិនិត្យ តាមដាន និងវាយតម្លៃការអនុវត្តកម្មវិធី និងគាំទ្រក្នុងការដោះស្រាយបញ្ហាប្រឈមដែលពាក់ព័ន្ធ
- ផ្តល់របាយការណ៍ ទិន្នន័យ ព័ត៌មាន និងផ្ទៀងទិន្នន័យផ្សេងៗ តាមការតម្រូវរបស់អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម។

**មាត្រា១៤**.-

ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ មានតួនាទី និងភារកិច្ចដឹកនាំការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ ជូនតាក្រោមសមត្ថកិច្ចរបស់ខ្លួន ដូចខាងក្រោម៖

- សម្របសម្រួលរៀបចំកម្មវិធីសិក្សា និងផ្តល់វគ្គបណ្តុះបណ្តាលជូនយុវជនគោលដៅ ប្រកបដោយប្រសិទ្ធភាព និងគុណភាព
- អនុវត្តការងារចាំបាច់សម្រាប់អនុវត្តកម្មវិធី ចាប់ពីថ្ងៃចុះឈ្មោះចូលរៀនក្នុងកម្មវិធី រហូតដល់ការផ្តល់សេវាប្រឹក្សាការងារ
- គ្រប់គ្រង និងសម្របសម្រួលជាមួយសាលាបណ្តុះបណ្តាល
- រៀងចំសៀវភៅប្រតិបត្តិគោលស្តីពីការអនុវត្តកម្មវិធី
- សហការជាមួយក្រសួង-ស្ថាប័ន និងភាគីពាក់ព័ន្ធ ដើម្បីដោះស្រាយមតិជំទាស់ និងការតវ៉ារបស់អ្នកទទួលផល
- សហការ និងចូលរួមដំណើរការពិនិត្យ តាមដាន និងវាយតម្លៃការអនុវត្តកម្មវិធី និងគាំទ្រក្នុងការដោះស្រាយបញ្ហាប្រឈមដែលពាក់ព័ន្ធ
- រៀបចំផែនការ និងប៉ាន់ស្មានតម្រូវការថវិកាសម្រាប់ការបណ្តុះបណ្តាល និងការផ្តល់សេវានានា ក្រោមកម្មវិធី
- ផ្តល់របាយការណ៍ ទិន្នន័យ ព័ត៌មាន និងផ្ទៀងទន្និន័យផ្សេងៗ តាមការតម្រូវរបស់អគ្គ-លេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម។

**មាត្រា១៥**.-

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដែលមានមូលនិធិជាតិជំនួយសង្គមជាប្រតិបត្តិករមានតួនាទី និងភារកិច្ច ដូចខាងក្រោម៖

- ធ្វើការទំនាក់ទំនង កៀរគរ និងបញ្ជ្រាបការយល់ដឹង និងព័ត៌មានអំពីកម្មវិធីដល់យុវជនគោលដៅ អាជ្ញាធរ មូលដ្ឋាន គ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ អង្គការ និងសមាគម
- បើកផ្តល់ប្រាក់ឧបត្ថម្ភ ប្រកបដោយប្រសិទ្ធភាព
- គ្រប់គ្រងដំណើរការប្រចាំថ្ងៃនៃការបើកផ្តល់ រួមទាំងកំណត់ និងគ្រប់គ្រងស្ថាប័ន និងភ្នាក់ងារបើកផ្តល់

- សហការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ ដើម្បីដោះស្រាយមតិជំទាស់ និងការតវ៉ារបស់អ្នកទទួលផល
- រៀបចំផែនការ និងប៉ាន់ស្មានតម្រូវការថវិកាសម្រាប់ការបើកផ្តល់សាច់ប្រាក់ឧបត្ថម្ភ និងចំណាយនានាក្រោមកម្មវិធី
- សហការ ចូលរួមតាមដាននិងវាយតម្លៃការអនុវត្តកម្មវិធី និងគាំទ្រការដោះស្រាយបញ្ហាពាក់ព័ន្ធ
- ផ្តល់របាយការណ៍ ទិន្នន័យ ព័ត៌មាន និងផ្ទៀងទិន្នន័យផ្សេងៗ តាមការតម្រូវរបស់អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម។

**មាត្រា១៦**.-

ក្រសួងផែនការ មានតួនាទី និងភារកិច្ច ដូចខាងក្រោម៖

- អនុវត្តការកំណត់អត្តសញ្ញាណគ្រួសារក្រីក្រតាមការស្នើសុំ និងធ្វើបច្ចុប្បន្នភាពទិន្នន័យជាប្រចាំ
- ផ្តល់ទិន្នន័យគ្រួសារមានបណ្ណសមធម៌ និងបណ្ណសម្គាល់គ្រួសារងាយរងហានិភ័យសម្រាប់ការអនុវត្តកម្មវិធី
- គាំទ្រការដោះស្រាយបញ្ហាដែលពាក់ព័ន្ធនឹងទិន្នន័យអត្តសញ្ញាណគ្រួសារមានបណ្ណសមធម៌ និងបណ្ណសម្គាល់គ្រួសារងាយរងហានិភ័យ
- សហការ និងចូលរួមដំណើរការពិនិត្យ តាមដាននិងវាយតម្លៃការអនុវត្តកម្មវិធី និងគាំទ្រការដោះស្រាយបញ្ហាប្រឈមដែលពាក់ព័ន្ធ។

**មាត្រា១៧**.-

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានតួនាទី និងភារកិច្ច ដូចខាងក្រោម៖

- ត្រួតពិនិត្យ ផ្តល់យោបល់ និងសម្រេចលើគម្រោងថវិកាសម្រាប់ការអនុវត្តកម្មវិធី
- វិភាជថវិកាសម្រាប់ការអនុវត្តកម្មវិធី
- ពិនិត្យរបាយការណ៍សកម្មភាពការងារហិរញ្ញវត្ថុ និងសមិទ្ធកម្មរបស់កម្មវិធី
- សហការ និងចូលរួមដំណើរការពិនិត្យ តាមដាន និងវាយតម្លៃការអនុវត្តកម្មវិធី និងគាំទ្រការដោះស្រាយបញ្ហាប្រឈមដែលពាក់ព័ន្ធ។

**មាត្រា១៨**.-

រដ្ឋបាលឃុំ សង្កាត់ មានតួនាទី និងភារកិច្ច ដូចខាងក្រោម៖

- ជំរុញការផ្សព្វផ្សាយ និងការបញ្ជ្រាបការយល់ដឹង និងព័ត៌មានអំពីកម្មវិធីដល់យុវជនគោលដៅ និងសាធារណជនក្នុងមូលដ្ឋាន
- ជំរុញ និងសម្របសម្រួលយុវជនឱ្យចុះឈ្មោះចូលរៀនក្នុងកម្មវិធី
- ជំរុញយុវជនគោលដៅដែលខកខានមិនបានទទួលការបញ្ចាក់លក្ខខណ្ឌសិក្សា ឱ្យត្រឡប់មកទទួលការបញ្ចាក់លក្ខខណ្ឌសិក្សាបន្ត។

## ជំពូកទី៥
## ថវិកាអនុវត្តកម្មវិធី

**មាត្រា១៩**.-

ថវិកាសម្រាប់អនុវត្តកម្មវិធីត្រូវហិរញ្ញប្បទានដោយថវិការដ្ឋ តាមរយៈមូលនិធិហិរញ្ញប្បទានគាំពារសង្គម (ម.គ.ស) និងថវិកាពីប្រភពស្របច្បាប់ផ្សេងទៀត។

ថវិការដ្ឋសម្រាប់អនុវត្តកម្មវិធីបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និងបច្ចេកទេស ត្រូវគ្រោង និងកត់ត្រានៅក្នុងក្របខណ្ឌនៃកញ្ចប់ថវិការបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងសម្រាប់អនុវត្តកម្មវិធីបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈដូនតា ត្រូវគ្រោង និងកត់ត្រានៅក្នុងក្របខណ្ឌនៃកញ្ចប់ថវិការបស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ។

មូលនិធិជាតិជំនួយសង្គម អាចស្នើសុំថវិកាចំណាយប្រតិបត្តិការសម្រាប់ការបើកផ្តល់សាច់ប្រាក់ឧបត្ថម្ភ តាមរយៈអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម (អ.ក.គ.) គោរពជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាជាតិគាំពារសង្គម ពិនិត្យ និងសម្រេច តាមការចាំបាច់។

**មាត្រា២០.-**

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ត្រូវបោះផ្សាយអាណត្តិឧបត្ថម្ភធននូវកញ្ចប់ថវិកាប្រចាំឆ្នាំសម្រាប់អនុវត្តកម្មវិធីនេះ នៅរៀងរាល់ត្រីមាស ឬតាមតម្រូវការចំណាយជាក់ស្តែង ដើម្បីរក្សាទុកក្នុងគណនីប្រាក់បញ្ញើរបស់ ម.គ.ស. នៅធនាគារជាតិនៃកម្ពុជា។

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងមូលនិធិជាតិជំនួយសង្គម ត្រូវរៀបចំស្នើសុំបុរេប្រទានប្រចាំត្រីមាស ឬតាមតម្រូវការចំណាយជាក់ស្តែង ដោយភ្ជាប់មកជាមួយនូវការគ្រោងចំណាយលម្អិត តាមរយៈអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម ដើម្បីលើកការស្នើសុំបុរេប្រទានថវិកាគោរពជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាជាតិគាំពារសង្គម ពិនិត្យ និងសម្រេច។

អ.ក.គ. រៀបចំផ្តល់បុរេប្រទានថវិកាជូន ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងមូលនិធិជាតិជំនួយសង្គម តាមរយៈមូលប្បទានបត្រ ឬការផ្ទេរសាច់ប្រាក់ចូលគណនីរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងមូលនិធិជាតិជំនួយសង្គម បន្ទាប់ពីទទួលបានការពិនិត្យ និងសម្រេចរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាជាតិគាំពារសង្គម ផ្តល់ថវិកាតាមការស្នើសុំ។

**មាត្រា២១.-**

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងមូលនិធិជាតិជំនួយសង្គម ត្រូវជម្រះចំណាយជាប្រចាំជាមួយ ម.គ.ស ដែលមាន អ.ក.គ. ជាសេនាធិការ និងធ្វើរបាយការណ៍បិទបញ្ជីចំណូល-ចំណាយប្រចាំឆ្នាំ ស្របតាមបទដ្ឋានគតិយុត្តហិរញ្ញវត្ថុជាធរមាន។

## ជំពូកទី៦

## របាយការណ៍ និងការចុះពិនិត្យការអនុវត្តកម្មវិធី

**មាត្រា២២.-**

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងមូលនិធិជាតិជំនួយសង្គម ត្រូវផ្តល់របាយការណ៍ស្តីពីវឌ្ឍនភាពនៃការអនុវត្តកម្មវិធីប្រចាំឆមាស និងប្រចាំឆ្នាំ ជូនអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម។

របាយការណ៍ប្រចាំឆមាស ត្រូវផ្តល់យ៉ាងយូរក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃ បន្ទាប់ពីដំណាច់ឆមាស។ របាយការណ៍ប្រចាំឆ្នាំ ត្រូវផ្តល់យ៉ាងយូរក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃ បន្ទាប់ពីដំណាច់ឆ្នាំនីមួយៗ។

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងមូលនិធិជាតិជំនួយសង្គម ត្រូវផ្តល់របាយការណ៍ផ្សេងទៀតពាក់ព័ន្ធនឹងការអនុវត្តកម្មវិធី តាមការស្នើសុំរបស់អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម។

**មាត្រា២៣**.-

ការអនុវត្តកម្មវិធីជាតិជំនួយសង្គមផ្នែកបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និងបច្ចេកទេស សម្រាប់យុវជនមកពីគ្រួសារក្រីក្រ និងគ្រួសារងាយរងហានិភ័យ ត្រូវស្ថិតនៅក្រោមអធិការកិច្ច និងសវនកម្មអនុលោមតាមបទប្បញ្ញត្តិជាធរមាន។

**មាត្រា២៤**.-

គណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រុមប្រឹក្សាជាតិគាំពារសង្គម មានសិទ្ធិចាត់មន្ត្រីជំនាញពាក់ព័ន្ធ ចុះពិនិត្យ និងសង្កេតជាក់ស្តែងដល់ទីកន្លែងអំពីប្រសិទ្ធភាពនៃការអនុវត្តកម្មវិធីនេះ។

## ជំពូកទី៧
## ករណីប្រធានសក្តិ

**មាត្រា២៥**.-

ក្នុងករណីប្រធានសក្តិ ឬមានវិបត្តិធ្ងន់ធ្ងរកើតឡើង ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងមូលនិធិជាតិជំនួយសង្គម ត្រូវស្នើសុំក្រុមប្រឹក្សាជាតិគាំពារសង្គម លើកលែងនូវការអនុវត្តលក្ខខណ្ឌ ឬលើកជាជម្រើសសមស្របផ្សេងទៀត ដើម្បីឱ្យអ្នកទទួលផលទទួលបានអត្ថប្រយោជន៍ពីការអនុវត្តកម្មវិធីជាតិជំនួយសង្គមផ្នែកបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និងបច្ចេកទេស សម្រាប់យុវជនមកពីគ្រួសារក្រីក្រ និងគ្រួសារងាយរងហានិភ័យ និងទទួលបានអត្ថប្រយោជន៍បន្ថែម។

## ជំពូកទី៨
## ការដោះស្រាយវិវាទ ឬបណ្តឹង

**មាត្រា២៦**.-

វិវាទ ឬបណ្តឹងដែលពាក់ព័ន្ធនឹងការអនុវត្តកម្មវិធី ត្រូវដោះស្រាយក្នុងកម្រិតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ មូលនិធិជាតិជំនួយសង្គម និងក្រសួងផែនការ តាមសមត្ថកិច្ចរៀងខ្លួន។ ក្នុងករណីមិនអាចដោះស្រាយបានក្នុងកម្រិតក្រសួង-ស្ថាប័ន វិវាទ ឬបណ្តឹង អាចត្រូវប្តឹងទៅអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម មុននឹងប្តឹងទៅតុលាការ។

## ជំពូកទី៩
## អវសានប្បញ្ញត្តិ

**មាត្រា២៧**.-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា២៨.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងផែនការ រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រដ្ឋមន្ត្រីគ្រប់ក្រសួង អគ្គនាយកមូលនិធិជាតិជំនួយសង្គម និងប្រធានគ្រប់ស្ថាប័ន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃអាទិត្យ ១៤រោច ខែអស្សុជ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០២៣

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី សូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**និងជាប្រធានក្រុមប្រឹក្សាជាតិគាំពារសង្គម**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២៨ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ